# ១.បរិស្ថានធម្មជាតរបស់ទន្លេមេគង្គ

## បរិស្ថានធម្មជាតនៅក្នុងអាងទន្លេមេគង្គ

ទន្លេមេគង្គគឺជាផ្លូវទឹកអន្តរជាតិមួយដែលមានប្រភពពីខ្ពង់រាបទីបេនិងហូរកាត់តាមដីសណ្តរ ទន្លេមេគង្គឆ្ពោះបន្តរហូតទៅដល់សមុទ្រចិនភាគខាងត្បូង។ទន្លេនេះសម្បូរទៅដោយជីវៈចម្រុះគ្រប់ប្លែទ ដែលជាប់ចំណាត់ថ្នាក់ទីពីរបន្ទាប់ពីទន្លេអាមាហ្សូន(Peterson និង Middleton ២០១០)។ក្រៅពីត្រី ដែលមាន៨៥០ប្រភេទទន្លេនេះក៏មានរុក្ខជាតិ២០,០០០ប្រភេទមានសត្វ៤៣០ប្រភេទមានដូចជាពពួក បក្សីចំនួន១,២០០ប្រភេទនិងពពួកល្មូននិងពពួកសត្វរស់នៅបានទាំងក្នុងទឹកនិងលើគោកចំនួន៨០០ ផ្សេងទៀតផងដែរ (Thompson២០០៨)។អាងទន្លេនេះទាំងមូលមានផ្ទៃក្រឡា៧៩៥,០០០គ.ម$^{២}$គឺស្មើ ពីរដងនៃផ្ទៃដីប្រទេសជប៉ុនដែលមានទំហំ៣៧៧,៩៤៧គ.ម$^{២}$និង មានបណ្តោយប្រវែង៤,៩០៩គ.ម ( MRCឆ្នាំ២០០០: ៥)។




*រូបភាពទី១៖ទន្លេមេគង្គ*

ចម្ងាយរវាងប្រភពទន្លេនិងដីសណ្តរនៅក្នុងប្រទេសជប៉ុនមានចម្ងាយខ្លីដោយឡែកទន្លេមេគង្គ ហូរក្នុងរយៈចម្ងាយមួយដ៏ឆ្ងាយ។លក្ខណៈពិសេសមួយទៀតរបស់ទន្លេមេគង្គគឺនៅត្រង់រយៈកម្ពស់របស់ វាធៀបជាមួយនីវ៉ូទឹកសមុទ្រដែលមិនមានភាពខុសគ្នាច្រើនរវាងប្រភពទន្លេនិងដីសណ្តរ។

ទន្លេមេគង្គហូរកាត់ប្រទេសចំនួន៦រួមមានប្រទេសចិន (ខេត្តQinghaiនិងខេត្តYunnan) ប្រទេសភូមា/មីយ៉ាន់ម៉ាប្រទេសឡាវប្រទេសថៃប្រទេសកម្ពុជានិងប្រទេសវៀតណាមហើយបន្ទាប់មកហូរចាក់ចូលទៅក្នុងសមុទ្រ។នៅក្នុងប្រទេសចិនភាគខាងលើក្បាលទន្លេដ៏ធំរបស់ក្នុងពិភពលោកចំនួនបីដែលរួមមានទន្លេYangtze ទន្លេមេគង្គនិងទន្លេSalween បានហូរប្រកៀកគ្នាដូចនេះហើយភូមិសាស្រ្តតំបន់នេះត្រូវបានគេហៅថាទន្លេស្របបី។បន្ទាប់មកទន្លេមេគង្គហូរចូលក្នុងប្រទេសឡាវតាមបណ្តោយព្រំដែនប្រទេសភូមា-ឡាវហើយក្រោយមកបន្ទាប់ពីហូរតាមបណ្តោយព្រំដែនថៃ-ឡាវទន្លេនេះបានហូរចូលក្នុងប្រទេសកម្ពុជាដែលជាកន្លែងតភ្ជាប់ជាមួយនឹងបឹងទន្លេសាបដែលជានិមិត្តរូបរបស់ប្រទេសកម្ពុជា។នៅចុងក្រោយទន្លេនេះហូរចូលក្នុងប្រទេសវៀតណាមដែលគេស្គាល់ថាជាទន្លេនាគប្រាំបួន។តំបន់ដីសណ្តរទន្លេមេគង្គនៅក្នុងប្រទេសវៀតណាមគឺជាតំបន់ផលិតស្រូវដ៏ធំបំផុតមួយរបស់ពិភពលោកហើយចាប់ពីទីនោះមកទន្លេមេគង្គហូរចាក់ចូលទៅក្នុងសមុទ្រចិនខាងត្បូង។

ទន្លេមេគង្គមានប្រភពមកពីការរលាយដុំទឹកកកនៅភ្នំHimalayas(ភ្នំហេមពាន្ត)ប៉ុន្តែទឹកដែលហូរពីផ្ទៃអាងផ្សេងៗនៅក្នុងប្រទេសចិនបានចូលរួមចំនែកដល់លំហូរទឹកទន្លេនេះចំនួន១៦% ប្រទេសភូមាចំនួន២%ប្រទេសឡាវចំនួន៣៥% ប្រទេសថៃចំនួន១៨%ប្រទេសកម្ពុជាចំនួន១៨% និងប្រទេសវៀតណាមចំនួន១១% (MRC ២០០៥) ។

| | ប្រទេសចិន | ប្រទេស ភូមា | ប្រទេសឡាវ | ប្រទេសថៃ | ប្រទេស កម្ពុជា | ប្រទេស វៀតណាម | ផ្ទៃអាងទឹក ទាំងមូល |
|---|---|---|---|---|---|---|---|
| ផ្ទៃអាងទឹក (គ.ម២) | ១៦៥,០០០ | ២៤,០០០ | ២០២,០០០ | ១៨៤,០០០ | ១៥៥,០០០ | ៦៥,០០០ | ៧៩៥,០០០ |
| ផ្ទៃអាងទឹក (គិតជា% នៃផ្ទៃរងទឹកភ្លៀង ទាំងមូល) | ២១ | ៣ | ២៥ | ២៣ | ២០ | ៨ | ១០០ |
| កម្រិតទឹក (គិតជា% នៃផ្ទៃរងទឹកភ្លៀង ទាំងមូល) | ១៦ | ២ | ៣៥ | ១៨ | ១៨ | ១១ | ១០០ |

*តារាង១៖ការប្រៀបធៀបផ្ទៃអាងទឹកទន្លេមេគង្គ រវាងប្រទេសទាំង៦ (MRC ឆ្នាំ២០០៥)*

អាងទន្លេមេគង្គទទួលរងឥទ្ធពលអាកាសធាតុពីខ្យល់មូសុងត្រូពិច។ចាប់ពីពាក់កណ្តាលខែឧសភាដល់ខែតុលាខ្យល់មូសុងនិរតីនាំមកនូវរដូវវស្សា។ចាប់ពីខែវិច្ឆិកាដល់ពាក់កណ្តាលខែមីនាតំបន់នេះ

ត្រូវរងឥទ្ធពលខ្យល់មូសុងឦសានដែលនាំមកនូវរដូវប្រាំង (MRC២០១០៖១៤)។រដូវប្រាំងនេះបន្តរហូតដល់ខែមេសាហើយបន្ទាប់មកនៅខែឧសភាភ្លៀងចាប់ផ្តើមធ្លាក់ដែលបង្ហាញពីការចាប់ផ្តើមនៃរដូវវស្សា។ក្រៅពីតំបន់នៅក្នុងប្រទេសចិនពេលវេលាដែលក្តៅបំផុតគឺនៅជុំវិញខែមេសា។




ដ្យាក្រាមទី២៖ សីតុណ្ហភាព និងកម្ពស់ទឹកភ្លៀងក្នុង ខេត្ត*អ៊ុប៊ុនរ៉ាតឆាថានី* (នាយកដ្ឋានឧត្តុនិយមខេត្ត*អ៊ុប៊ុនរ៉ាតឆាថានី* ប្រទេសថៃ ២០០៤)

កម្រិតទឹកភ្លៀងធ្លាក់ប្រចាំឆ្នាំនៅក្នុងខេត្តអ៊ុប៊ុនរ៉ាតឆាថានី(UbonRatchathani)ភាគឥសាននៃប្រទេសថៃមានកម្ពស់១,៥០០ម.ម។ ចំនួននេះប្រហាក់ប្រហែលគ្នានឹងទីក្រុងតូក្យូដែរ ប៉ុន្តែក្នុងករណីមួយដូចមានបង្ហាញក្នុងដ្យាក្រាមទី២មានភ្លៀងធ្លាក់ខ្លាំងនៅចន្លោះខែឧសភានិងខែកញ្ញា។ចាប់ពីខែតុលារហូតដល់ដើមរដូវវស្សាក្នុងខែឧសភាពឆ្នាំបន្ទាប់មានភ្លៀងធ្លាក់តិចតួចបំផុត។ទន្លេមូន (Mun River)ដែលហូរកាត់តាមខេត្តអ៊ុប៊ុនរ៉ាតឆាថានីត្រូវទទួលរងឥទ្ធិពលពីលំនាំទឹកភ្លៀងនេះដូច្នេះកម្រិតទឹកចាប់ផ្តើមកើនឡើងនៅក្នុងខែឧសភានិងបន្តឡើងដល់កម្រិតខ្ពស់បំផុតនៅក្នុងខែតុលា។បន្ទាប់មកចាប់ពីខែវិច្ឆិកាដល់ខែមេសាកម្រិតទឹកចាប់ផ្តើមស្រកចុះបន្តិចម្តងៗវិញ។

មានតែទន្លេមេនៃអាងទន្លេមេគង្គទាំងមូលប៉ុណ្ណោះដែលទទួលបានទឹកពីការរលាយទឹកកកនៅភ្នំ Himalayas(ភ្នំហេមពាន្ត) ដូចនេះកម្រិតទឹករបស់ទន្លេមេនេះចាប់ផ្តើមកើនឡើងនៅក្នុងខែមេសា។ការប្រែប្រួលលក្ខណៈទាំងអស់នេះបង្កើតបានជាមូលដ្ឋាននៃបរិស្ថានធម្មជាតិដ៏វិសេសនិងប្រព័ន្ធជីវៈចម្រុះដ៏កម្រជាច្រើនប្រភេទផ្សេងៗគ្នានៅក្នុងអាងទន្លេមេគង្គ។

**ឯកសារយោង**

Mekong River Commission (MRC). 2005. *Overview of the Hydrology of the Mekong Basin.*
http://www.mekonginfo.org/assets/midocs/0001968-inland-waters-overview-of-the-hydrology-of-the-mekong-basin.pdf

Mekong River Commission (MRC). 2010. *State of the Basin Report 2010.*
http://www.mrcmekong.org/assets/Publications/basin-reports/MRC-SOB-report-2010full-report.pdf

Peterson, B., and C. Middleton. 2010. *Feeding Southeast Asia: Mekong River Fisheries and Regional Food Security.* Berkeley, California: International Rivers (IR).
http://www.internationalrivers.org/files/attached-files/intrivers_mekongfoodsecurity_jan10.pdf

Thompson, C. 2008. *First Contact in the Grater Mekong*.World Wildlife Fund (WWF) Greater Mekong Programme.
http://awsassets.panda.org/downloads/first_contact_final_report.pdf
Tone River Management Office of the Ministry of Land, Infrastructure, Transport, and Tourism, Kanto Regional Development Bureau.
*What are the Unique Characteristics of Japan's Rivers?* (in Japanese).
http://www.ktr.mlit.go.jp/tonedamu/tonedamu00082.html (Last accessed on September 30, 2012)

ឃិគូឈិយូកា